ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-២០២ ប្រ.ក

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតនិងកំណត់មុខងារ-ភារកិច្ចរបស់គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅពង្រឹងការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមដានការអនុវត្តច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដើម្បីរក្សាប្រព័ន្ធធនាគារឲ្យមានសុវត្ថិភាពនិងភាពរឹងមាំ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

សមាសភាពគណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានដូចខាងក្រោម៖

- អគ្គនាយកត្រួតពិនិត្យ ជាប្រធាន
- អគ្គនាយករងត្រួតពិនិត្យ ជាអនុប្រធាន
- អគ្គនាយករងត្រួតពិនិត្យ ជាសមាជិក
- ប្រធាននាយកដ្ឋាននីតិកម្ម ជាសមាជិក
- ប្រធាននាយកដ្ឋានអាជ្ញាប័ណ្ណ ជាសមាជិក
- ប្រធាននាយកដ្ឋានត្រួតពិនិត្យលើឯកសារ ជាសមាជិក
- ប្រធាននាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង ជាសមាជិក។

**ប្រការ ៤.-**

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលបានសិទ្ធិអំណាចពីទេសាភិបាលធនាគារជាតិនៃកម្ពុជាដើម្បីអនុវត្តការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងកម្រិតដាច់ដោយឡែកនិងគួបសរុប(on individual and consolidated level)ដូចខាងក្រោម៖

- ការអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមាន
- ធ្វើចំណាត់ថ្នាក់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ពិនិត្យ ពិភាក្សានិងដាក់ចេញអនុសាសន៍ និងវិធានការកែតម្រូវ
- តាមដានការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ចេញសេចក្តីសម្រេចលើការងាររដ្ឋបាលដែលពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង
- បំពេញការងារចាំបាច់ផ្សេងទៀតដែលទេសាភិបាលប្រគល់ឲ្យ។

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានកាតព្វកិច្ចអនុវត្តការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាពលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគតនិងគួបសរុប (Risk-based and forwarded looking and consolidated supervision)។

ក្នុងករណីពិនិត្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានបញ្ហាប្រឈមជាប្រព័ន្ធ លទ្ធភាពនៃការជាប់ពាក់ព័ន្ធ និងការបង្ករជាប្រព័ន្ធ គណៈកម្មការនេះត្រូវលើកសំណើទៅគណៈកម្មការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច។

**ប្រការ ៥.-**

ប្រធានគណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់អំពីសកម្មភាពរបស់គណៈកម្មការ តាមការកំណត់របស់ទេសាភិបាល។

**ប្រការ ៦.-**

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវជួបប្រជុំមួយខែម្ដង ឬច្រើនដងតាមការចាំបាច់។

កិច្ចប្រជុំរបស់គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកយ៉ាងតិចប្រាំរូប។

មន្ត្រីជំនាញអាចត្រូវអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការតាមការចាំបាច់។

ក្នុងករណីអវត្តមានប្រធាន កិច្ចប្រជុំរបស់គណៈកម្មការត្រូវដឹកនាំដោយអនុប្រធានមួយរូប។

**ប្រការ ៧.-**

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងសមាជិកត្រូវទទួលបានការការពារផ្នែកច្បាប់ពីធនាគារជាតិនៃកម្ពុជា ជាក្រុម ឬឯកត្តជនចំពោះសកម្មភាពនានាដែលបានអនុវត្តក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវគោរពតាមគោលការណ៍និងការហាមឃាត់ដែលមានចែងនៅក្នុងក្រមសីលធម៌។

**ប្រការ ៨.-**

គណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវមានក្រុមលេខាធិការជាជំនួយការ។

ក្រុមលេខាធិការមានមុខងារ-ភារកិច្ចដូចខាងក្រោម៖

- រៀបចំរបៀបវារៈប្រជុំ
- រៀបចំសំណុំឯកសារប្រជុំ
- រៀបចំកំណត់ហេតុប្រជុំ និងត្រូវជានាការសម្ងាត់ និង
- បំពេញការងារផ្សេងទៀត ដែលប្រធានគណៈកម្មការប្រគល់ឲ្យ។

កំណត់ហេតុនៃអង្គប្រជុំត្រូវផ្ដល់ជូនទេសាភិបាលតែប៉ុណ្ណោះ។ កំណត់ហេតុមិនត្រូវផ្ដល់ជូនតតិយជន ឬសាធារណៈជនទូទៅឡើយ។

**ប្រការ ៩.-**

ប្រកាសលេខ ធ៧-០១៣-២២២ ប្រ.ក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ស្ដីពីការបង្កើតគណៈកម្មការប្រតិបត្តិការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងសាមីជនខាងលើ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧

**អគ្គទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល៖**

-ដូចប្រការ ៣ និងប្រការ ១០ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ចម្លងជូន ៖**

-គ្រប់សមាជិកក្រុមប្រឹក្សាភិបាល

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"